# គោលការណ៍សិទ្ធិឯកជន

កែប្រែចុងក្រោយៈ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣

គោលការណ៍សិទ្ធិឯកជនរបស់ Starbucks ("គោលការណ៍") បានពិពណ៌នាអំពីរបៀបដែល Coffee Concepts (Cambodia) Limited ប្រគល់សិទ្ធិឲ្យអ្នកទទួលអាជ្ញាប័ណ្ណរបស់សាជីវកម្ម Starbucks ក្នុងប្រទេសកម្ពុជា (សំដៅទៅលើ "Starbucks" ខាងក្រោម) ប្រើប្រាស់ និងបង្ហាញព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជន ដែលប្រមូលបានតាមរយៈគេហទំព័រ និងតាមរយៈសេវាកម្មអនឡាញរបស់យើង រួមបញ្ចូលទាំងគេហទំព័រ Starbucks.com.kh កម្មវិធីទូរស័ព្ទ Starbucks® Cambodia ហើយនិងគេហទំព័រ និងសេវាកម្មអនឡាញដែលជាកម្មសិទ្ធិ ឬដំណើរការដោយ Starbucks ដែលបានធ្វើតំណភ្ជាប់ទៅគោលការណ៍នេះ (រួមគ្នាហៅថា "គេហទំព័រ") តាមរយៈកម្មវិធី និងហាងបម្រើអាជីវកម្មរបស់ Starbucks ("សេវាកម្ម") ។ គោលការណ៍នេះមិនប្រើប្រាស់ចំពោះគេហទំព័រ និងសេវាកម្មដែលបានបង្ហាញ ឬមានតំណភ្ជាប់ទៅការបញ្ជាក់ឯកជនផ្សេងទៀតឡើយ ។ គេហទំព័រ និងសេវាកម្មដែលមានម៉ាករួមគ្នាជាមួយដៃគូផ្សេងទៀត អាចបង្ហាញ ឬមានតំណភ្ជាប់ទៅការបញ្ជាក់ជាឯកជនរួមគ្នា ឬដាច់ដោយឡែកពីការបញ្ជាក់ជាឯកជនរបស់ដៃគូរបស់យើង ទៅលើគោលការណ៍របស់យើង ។ តាមរយៈការចូលទៅគេហទំព័រ ឬប្រើប្រាស់សេវាកម្ម ចាប់ពីពេលនេះទៅអ្នកយល់ព្រមប្រើប្រាស់ព័ត៌មានរបស់អ្នក រួមទាំងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ព័ត៌មានអ្នកផ្សេងទៀតដែលត្រូវបានផ្តល់ដោយអ្នក ក្នុងរបៀបដែលបានរៀបរាប់នៅក្នុងគោលការណ៍នេះ ។ ដោយគ្មានការកម្រិតពីភាពទូទៅនៃការបន្តទៅមុខ អ្នកផ្តល់សិទ្ធិអំណាចឲ្យ Starbucks បញ្ជូនព័ត៌មានរបស់អ្នកចេញពីប្រទេសកម្ពុជាក្នុងអាកប្បកិរិយា និងបំណងដែលមាននៅក្នុងគោលការណ៍នេះ ។

តើព័ត៌មានបៀបណាដែល Starbucks ត្រូវការ?

ព័ត៌មានផ្ទាល់ខ្លួនដែល Starbucks ត្រូវការរួមមាន៖

- ឈ្មោះ អាសយដ្ឋានតាមប្រៃសណីយ៍ លេខទូរស័ព្ទ និងអាសយដ្ឋានអ៊ីម៉ែល ។
- ព័ត៌មានពីគណនីហិរញ្ញវត្ថុ ដូចជាលេខប័ណ្ណឥណទាន និងព័ត៌មានបង់ប្រាក់ផ្សេងទៀត ។

យើងក៏អាចប្រមូលព័ត៌មានពីអ្នកដូចជា៖

- ប្រសិនបើអ្នកបង្កើតគណនី - ឈ្មោះ ឈ្មោះបម្រាប់ចូលគណនី លេខសម្ងាត់ អ៊ីម៉ែល ថ្ងៃខែកំណើត ភេទ អាសយដ្ឋានបច្ចុប្បន្ន និងលេខទូរស័ព្ទរបស់អ្នក ។
- ប្រសិនបើអ្នកទិញទំនិញនៅក្នុងហាងរបស់យើង ឬតាមរយៈកម្មវិធីរបស់យើង ឬតាមអ្វីផ្សេងទៀត តើអ្នកទិញអ្វី តើអ្នកទិញនៅកន្លែងណា តើអ្នកទិញវាញឹកញាប់ទេ រង្វាន់ដែលអ្នកទទួលបាន និងរង្វាន់ដែលអ្នកបានប្តូរ ។
- ប្រសិនបើអ្នកចុះឈ្មោះកាត Starbucks ណាមួយ - លេខកាត ប្រវត្តិប្រតិបត្តិការកាត រួមបញ្ចូលទាំងការធ្វើឲ្យកាត Starbucks ដំណើរការ ការបញ្ចូលទឹកប្រាក់ទៅក្នុងកាត Starbucks ការប្តូរយករង្វាន់ ការផ្ទេរសមតុល្យ និងចរន្តសមតុល្យនានា

- ប្រសិនបើអ្នកប្រើប្រាស់កម្មវិធីទូរស័ព្ទរបស់យើងខ្ញុំ- ទិន្នន័យអំពីលេខអត្តសញ្ញាណឧបករណ៍ ទីតាំងរបស់លោកអ្នក និងហាងដែលនៅក្បែរអ្នក ហាងដែលអ្នកបានចូល អាចនឹងត្រូវប្រមូលយក ។
- ប្រសិនបើអ្នកបានធ្វើការស្ទង់មតិ ឬមានអន្តរកម្មរវាងយើងតាមរយៈវិធីផ្សេងៗ ព័ត៌មានប្រជាសាស្ត្រ មតិរបស់អ្នក យោបល់ សំណួរ ឬការស្នើជាយោបល់ និងព័ត៌មានអំពីកម្មវត្ថុដែលអ្នកចាប់អារម្មណ៍ ។

ហាង Starbucks ទាំងអស់នៅកម្ពុជា ត្រូវបានឃ្លាំមើលយ៉ាងជាប់លាប់ដោយកាមេរ៉ា ដែលថតយកទាំងរូបភាពនិងវីដេអូរបស់បុគ្គលទាំងឡាយណាដែលនៅក្នុង និងជុំវិញហាង ។

## ការប្រមូលទិន្នន័យដោយស្វ័យប្រវត្តិតាមរយៈ Cookies និង Web Beacons

យើងអាចប្រមូលព័ត៌មានតាមរយៈការប្រើប្រាស់អនឡាញដោយស្វ័យប្រវត្តិ នៅពេលអ្នកចូលទៅកាន់គេហទំព័ររបស់យើង ឬប្រើប្រាស់សេវាកម្មរបស់យើងខ្ញុំ ។ ព័ត៌មាននេះអាចរួមបញ្ចូលទាំងព័ត៌មានអំពីអ្នកផ្តល់សេវាកម្មអ៊ីនធើណេតរបស់អ្នក ប្រព័ន្ធដំណើរការរបស់អ្នក ប្រភេទកម្មវិធីអ៊ីនធើណេត (browser type) ឈ្មោះ domain អាសយដ្ឋានអ៊ីនធើណេត Protocol (IP) ពេលវេលានៃការចូលរបស់អ្នក គេហទំព័រដែលតាមរយៈអ្នកទៅកាន់យើងខ្ញុំ គេហទំព័រដែលអ្នកស្នើសុំ ហើយថ្ងៃខែ និងពេលវេលានៃការស្នើសុំទាំងនោះ ។ ការប្រមូលព័ត៌មានតាមរយៈការប្រើប្រាស់អនឡាញរបស់យើង អាចពាក់ព័ន្ធនឹងការប្រើប្រាស់ Cookies និង Web Beacon ។ Cookies គឺជាកន្លែងផ្ទុកទិន្នន័យតូចមួយដែលតម្លើងនៅក្នុង hard drive ដោយគេហទំព័រ ។ ក្នុងចំណោមនោះ Cookies អាចជួយយើងធ្វើឲ្យប្រសើរឡើងចំពោះគេហទំព័ររបស់យើង និងបទពិសោធន៍របស់អ្នក ។ យើងប្រើប្រាស់ Cookies សម្រាប់មើលតំបន់ ឬកម្មវិធីពិសេសដែលល្បីឈ្មោះ និងសម្រាប់រាប់ចំនួនអ្នកដែលចូលមកទស្សនាគេហទំព័ររបស់យើង ។ Web beacon គឺជាទ្រង់ទ្រាយអេឡិចត្រូនិចដែលប្រើនៅក្នុងគេហទំព័រ ឬអ៊ីម៉ែលរបស់យើង ។ យើងប្រើ Web beacon សម្រាប់ផ្ញើទៅ Cookies រាប់ចំនួនអ្នកចូលមកទស្សនា ប្រើប្រាស់ជាការយល់ដឹង និងធ្វើការផ្សព្វផ្សាយដ៏មានប្រសិទ្ធភាព និងដើម្បីប្រាប់ថាមានអ៊ីម៉ែលត្រូវបានបើក និងប្រើប្រាស់បន្ទាប់ទៀត ។ យើងនឹងប្រើប្រាស់ផងដែរនូវការចែករំលែក Flash Cookie ។ ដើម្បីធ្វើការកត់សម្គាល់ Local Shared Objects នៅក្នុងកុំព្យូទ័ររបស់អ្នក និងការផ្លាស់ប្តូរមុខងារ សូមចូលទៅកាន់៖

www.macromedia.com/support/documentation/en/flashplayer/help/settings_manager.html

Starbucks ក៏អាចចងក្រងប្រមូលទិន្នន័យ ឬទាញយកទិន្នន័យដែលមិនបញ្ជាក់ដោយផ្ទាល់ចំពោះអ្នក ។

យើងអាចនឹងច្របាច់បញ្ចូលព័ត៌មាន ដែលយើងប្រមូលបានពីអ្នកជាមួយព័ត៌មានដែលទទួលបានពីតតិយជន ។

**តើ Starbucks នឹងប្រើប្រាស់ព័ត៌មានរបស់អ្នករបៀបណា?**

Starbucks អាចប្រើប្រាស់ព័ត៌មានរបស់អ្នក សម្រាប់គោលបំណង ដែលពិពណ៌នានៅក្នុងគោលការណ៍នេះ ឬសម្រាប់បង្ហាញទៅអ្នកក្នុងគេហទំព័ររបស់យើង ឬជាមួយសេវាកម្មរបស់យើង។ ឧទាហរណ៍ យើងនឹងប្រើព័ត៌មានរបស់អ្នក ដើម្បី៖

- ដំណើរការ និងគ្រប់គ្រងការទិញរបស់អ្នក និងប្រើប្រាស់ផលិតផល និងសេវាកម្មរបស់ Starbucks រួមបញ្ចូលទាំងគណនី និងការចូលរួមកម្មវិធី និងការប្រើប្រាស់គេហទំព័ររបស់អ្នក ។
- ឆ្លើយតបទៅនឹងចម្ងល់របស់លោកអ្នក អំពីសេវាកម្មអតិថិជនរបស់យើងខ្ញុំ ដាក់បង្ហាញពីមតិ ឬយោបល់របស់អ្នកនៅក្នុងប្លុក ឬវេទិកាអនឡាញដែលមាននៅក្នុងគេហទំព័របស់យើង ឬចាត់វិធានការណ៍ផ្សេងទៀតដើម្បីឆ្លើយតបទៅនឹងចម្ងល់របស់អ្នក ឬសកម្មភាពរបស់អ្នកនៅក្នុងគេហទំព័រ ។
- ការបង្កើតការផ្សព្វផ្សាយសម្រាប់អ្នក តាមរយៈការច្របាច់បញ្ចូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកជាមួយព័ត៌មានដែលមិនមែនជាព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ដូចជាចំនួន និងប្រភេទដែលអ្នកបានទិញ ឬអត្ថប្រយោជន៍ផ្សេងទៀតដែលអ្នកបានទទួលតាមរយៈកម្មវិធីរបស់យើង ។
- ការទំនាក់ទំនងជាមួយអ្នកតាមរយៈ ប្រៃសណីយ៍ ទូរស័ព្ទ អ៊ីម៉ែល សារជាអក្សរ និង/ឬតាមរយៈគណនីកាត Starbucks និង/ឬកម្មវិធីទូរស័ព្ទ Starbucks® Cambodia របស់អ្នក (រួមបញ្ចូលជាមួយ ហើយមិនកំណត់ត្រឹមតែ សេវាផ្ញើសារក្នុងកម្មវិធីទូរស័ព្ទតែមួយមុខប៉ុណ្ណោះឡើយ) ស្តីអំពីការកុម្ម៉ង់ ឬទិញរបស់អ្នក សេវាកម្មរបស់អ្នក គណនី និងការចូលរួមកម្មវិធី ការប្រកួត ឬការចាប់ឆ្នោតដែលអ្នកបានចូលរួម និងព័ត៌មានដែលអ្នកបានស្នើសុំ ។
- ការទំនាក់ទំនងជាមួយអ្នកតាមរយៈ ប្រៃសណីយ៍ ទូរស័ព្ទ អ៊ីម៉ែល សារជាអក្សរ និង/ឬតាមរយៈគណនីកាត Starbucks និង/ឬកម្មវិធីទូរស័ព្ទ Starbucks® Cambodia របស់អ្នក (រួមបញ្ចូលជាមួយ ហើយមិនកំណត់ត្រឹមតែ សេវាផ្ញើសារក្នុងកម្មវិធីទូរស័ព្ទតែមួយមុខប៉ុណ្ណោះឡើយ) ស្តីអំពីម៉ាករបស់យើង ផលិតផល ព្រឹត្តិការណ៍ ឬគោលបំណងផ្សព្វផ្សាយផ្សេងៗ រួមបញ្ចូលទាំងការផ្តល់ជូនឲ្យនូវការសហការម៉ាក និងសម្ព័នភាពជាដៃគូ ។
- សម្រាប់ដំណើរការផ្ទៃក្នុង រួមបញ្ចូលទាំងការដោះស្រាយបញ្ហា វិភាគទិន្នន័យ ការសាកល្បង ការស្រាវជ្រាវ និងកែលម្អសេវាកម្ម ។

ទិន្នន័យដែលប្រមូលបានពីអ្នក អាចនឹងត្រូវបញ្ជូនទៅ និងដាក់នៅទីតាំងខាងក្រៅប្រទេសកម្ពុជា ។

**តើ Starbucks ចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ជាមួយតតិយជនដែរឬទេ?**

Starbucks ចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ក្នុងរបៀបដែលមានដែនកំណត់ ។

- យើងអាចនឹងចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកជាមួយអ្នកដទៃ ប្រសិនបើមានការយល់ព្រមពីអ្នក ។
- យើងអាចនឹងចែករំលែកព័ត៌មានជាមួយសាជីវកម្ម Starbucks និងបុគ្គលសម្ព័ន្ធរបស់ខ្លួន និងអ្នកដែលទទួលបានអាជ្ញាប័ណ្ណ និងក្រុមហ៊ុនមេ និងក្រុមហ៊ុនចំណុះ ។
- យើងក៏អាចនឹងចែករំលែកព័ត៌មានជាមួយក្រុមហ៊ុន ដែលផ្តល់ការគាំទ្រផ្នែកសេវាកម្មឲ្យយើង (ដូចជាភ្នាក់ងារប័ណ្ណឥណទាន ឬអ្នកផ្តល់សេវាកម្មបង់ប្រាក់ផ្សេងទៀត អ្នកផ្ញើសំបុត្រតាមប្រៃសណីយ៍ ឬអ្នកបម្រើសេវាគេហទំព័រ) និង/ឬភាគីទីបីដទៃទៀត ដែលអាចជួយយើងឲ្យលក់ផលិតផល និងសេវាកម្មរបស់យើងនៅលើទីផ្សារ និងជួយយើងក្នុងការទំនាក់ទំនង (ដោយផ្ទាល់ ឬប្រយោល) ជាមួយអតិថិជនរបស់យើង (ដូចជា អ្នកលក់តាមអ៊ីម៉ែល និងបណ្តាញសង្គម និងបណ្តាញភ្ជាប់ទំនាក់ទំនងផ្សេងៗ) ។ ក្រុមហ៊ុន/ភាគីទីបីទាំងនេះ អាចប្រើប្រាស់ព័ត៌មានរបស់អ្នក ដើម្បីបំពេញមុខងាររបស់ក្រុមហ៊ុនជំនួសឲ្យយើងខ្ញុំ ។
- យើងអាចនឹងបង្ហាញព័ត៌មានជាក់លាក់ (i) តាមរយៈការតម្រូវនៃច្បាប់ ឆ្លើយតបនឹងដំណើរការច្បាប់ និងពេលដែលតម្រូវឲ្យគោរពទៅតាមច្បាប់ (ii) ដើម្បីអនុវត្តកិច្ចព្រមព្រៀងរបស់យើងជាមួយអ្នកឲ្យមានប្រសិទ្ធភាព គោលការណ៍សហប្រតិបត្តិការរួមគ្នារបស់យើង និងបទបញ្ញត្តិដែលទាក់ទងនឹងការប្រើប្រាស់ផលិតផល និងសេវាកម្ម Starbucks របស់អ្នក តាមរយៈគេហទំព័រ ឬសេវាកម្ម ឬ (iii) ដើម្បីការពារសិទ្ធិ ទ្រព្យសម្បត្តិ ឬសុវត្ថិភាពរបស់ Starbucks ក្រុមហ៊ុនចំណុះ ក្រុមហ៊ុនសាជីវកម្ម Starbucks បុគ្គលសម្ព័ន្ធរបស់ខ្លួន និងអ្នកទទួលអាជ្ញាប័ណ្ណ និយោជិតរបស់យើង ភ្នាក់ងារ អតិថិជន និងអ្នកផ្សេងៗទៀត ។
- ប្រសិនបើអ្នកចូលរួមនៅក្នុងប្លុកណាមួយ ឬវេទិកាប្រព័ន្ធអនឡាញផ្សេងទៀតនៅក្នុង គេហទំព័ររបស់យើង ព័ត៌មានផ្ទាល់ខ្លួនដែលអ្នកបានដាក់បង្ហាញនៅក្នុងគេហទំព័ររបស់យើង អាចនឹងត្រូវបានចែករំលែកជាមួយអ្នក ដែលចូលរួមវេទិកានោះ និងអ្នកដែលចូលមកទស្សនាគេហទំព័រ ។
- នៅក្នុងករណីរួមបញ្ចូលគ្នា លទ្ធកម្ម ហិរញ្ញប្បទាន ឬលក់ទ្រព្យសម្បត្តិ ឬស្ថានភាពផ្សេងទៀតដែលពាក់ព័ន្ធនឹងការផ្ទេរនៃផ្នែកខ្លះ ឬទាំងអស់នៃទ្រព្យសម្បត្តិអាជីវកម្មរបស់យើង Starbucks អាចនឹងបង្ហាញ ឬផ្ទេរព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ទៅកាន់ភាគីដែលពាក់ព័ន្ធក្នុងការចរចារ ។

យើងក៏អាចនឹងធ្វើការចែករំលែកព័ត៌មានដែលបានចងក្រង ឬព័ត៌មានដែលបានដកចេញ ដែលមិនបានបញ្ជាក់ដោយផ្ទាល់ទៅអ្នក ។

## តើជម្រើសអ្វីដែល Starbucks ផ្តល់ឲ្យអំពីព័ត៌មានផ្ទាល់ខ្លួន?

Starbucks ផ្តល់ជម្រើសសម្រាប់អ្នកក្នុងការស្នើសុំដើម្បីចូល ធ្វើបច្ចុប្បន្នភាព ឬផ្លាស់ប្តូរព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក និងរបៀបនៃការទំនាក់ទំនងរបស់យើងជាមួយអ្នក ។ នេះគឺជារបៀបខ្លះៗ ដែលអ្នកអាចស្នើសុំក្នុងការផ្លាស់ប្តូរ៖

- ធ្វើតាមការណែនាំស្តីពីជម្រើសដកខ្លួនចេញ នៅក្នុងអ៊ីម៉ែលផ្សព្វផ្សាយដែលយើងបានផ្ញើទៅអ្នក ឬទាក់ទងទៅកាន់ Starbucks Cambodia (ព័ត៌មានលម្អិតអំពីលេខទំនាក់ទំនងមាននៅខាងក្រោម) ។
- ចុះឈ្មោះនៅក្នុងគណនី Starbucks.com.kh របស់អ្នក ប្រសិនបើអ្នកមាន និងចូលទៅកាន់ផ្នែកគ្រប់គ្រងចំណាប់អារម្មណ៍ទូទៅ ដើម្បីធ្វើការគ្រប់គ្រងព័ត៌មានលេខទំនាក់ទំនងរបស់អ្នក (ឧទាហរណ៍ អ៊ីម៉ែល និងអាសយដ្ឋានប្រៃសណីយ៍) ចំណង់ចំណូលចិត្ត និងធ្វើបច្ចុប្បន្នភាពព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ។
- សូមទំនាក់ទំនងមកកាន់យើងខ្ញុំតាមទូរស័ព្ទលេខ ០២៣ ៩៨៦ ៥៩១

ប្រសិនបើអ្នកធ្វើការជ្រើសរើសជម្រើសដកខ្លួនចេញពីការទទួលការទាក់ទងផ្សព្វផ្សាយពីយើង យើងនឹងអាចនៅតែផ្ញើទៅអ្នកនូវការទាក់ទង ដែលមិនមានជាការផ្សព្វផ្សាយ ដូចជាអ៊ីម៉ែលអំពីគណនីរបស់អ្នក ឬព័ត៌មានពីអាជីវកម្មរបស់យើង ឬព័ត៌មានអំពីសមាជិកភាពរបស់អ្នក ។

អ្នកអាចធ្វើការជ្រើសរើសរៀបចំកម្មវិធីសម្រាប់មើល ឬអានឯកសារលើអ៊ីនធើណេតរបស់អ្នក ដើម្បីរំលឹកអ្នកនៅពេលដែល Cookies ត្រូវបានផ្ញើទៅ ឬដើម្បីធ្វើការដកចេញ ឬបដិសេធ Cookies ។ កម្មវិធីសម្រាប់មើល ឬអានឯកសារលើអ៊ីនធើណេតនីមួយៗមានការខុសប្លែកគ្នាបន្តិច ដូច្នេះសូមមើលកម្មវិធីសម្រាប់មើល ឬអានឯកសារលើអ៊ីនធើណេតនៅលើ Help menu ដើម្បីធ្វើការសិក្សាឲ្យបានត្រឹមត្រូវដើម្បីកែសម្រួលបរិវេណ Cookies របស់អ្នក ។ ប្រសិនបើអ្នកជ្រើសរើសយក Cookies ចេញ ឬបដិសេធ Cookies វានឹងប៉ះពាល់ដល់កម្មវិធីពិសេសជាច្រើន ឬសេវាកម្មរបស់យើងនៅលើគេហទំព័រ ។

Starbucks នឹងមិនរក្សាទុកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នករយៈពេលមួយឆ្នាំ បន្ទាប់ពីបានបញ្ចប់គណនីរបស់អ្នក ឬកាត Starbucks ហើយព័ត៌មាននេះនឹងត្រូវលុបចោលចាប់ពីពេលនេះទៅ ។ ព័ត៌មានអ្នកផ្សេងទៀតដែលអ្នកផ្តល់ឲ្យ នឹងត្រូវបានលុបចោល បន្ទាប់ពីបានបញ្ចប់គោលបំណងសម្រាប់ការផ្តល់ព័ត៌មាននេះ ។

## តើព័ត៌មានផ្ទាល់ខ្លួនត្រូវបានធានាដោយរបៀបណា?

Starbucks នឹងចាត់វិធានការណ៍សមស្របដើម្បីរក្សារូបរាង បច្ចេកវិទ្យា និងសន្តិសុខរដ្ឋបាលឲ្យបានត្រឹមត្រូវ ដើម្បីជួយទប់ស្កាត់ការបាត់បង់ ការប្រើប្រាស់ខុសច្បាប់ ការចូលដោយគ្មានការអនុញ្ញាត ការបង្ហាញ ឬកែសម្រួលព័ត៌មានផ្ទាល់ខ្លួន ។

ក្នុងអំឡុងពេលដែលយើងចាត់វិធានការណ៍សមស្របទាំងនេះ ដើម្បីការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក និងព័ត៌មានអ្នកផ្សេងទៀតដែលអ្នកបានផ្តល់ឲ្យយើង គ្មានប្រព័ន្ធ ឬទិន្នន័យបញ្ជូនព័ត៌មាននៅលើអ៊ីនធើណេត ឬបណ្តាញសាធារណៈផ្សេងទៀតណាមួយ អាចធានាសុវត្ថិភាពបាន១០០%ទេ ។

## បច្ចុប្បន្នភាពនៃគោលការណ៍សិទ្ធិឯកជន

យើងអាចនឹងធ្វើបច្ចុប្បន្នភាពគោលការណ៍សិទ្ធិឯកជននេះ ចាប់ពីពេលនេះទៅពេលអនាគត ។ នៅពេលដែលយើងធ្វើដូច្នេះ យើងនឹងដាក់បង្ហាញគោលការណ៍សិទ្ធិឯកជនថ្មីនៅក្នុងគេហទំព័រនេះ និងផ្លាស់ប្តូរថ្ងៃខែនៅលើគោលការណ៍នេះ ។
យើងលើកទឹកចិត្តអ្នកធ្វើការពិនិត្យថ្ងៃខែនៃគោលការណ៍សិទ្ធិឯកជនរបស់យើង ពេលដែលអ្នកចូលមកទស្សនាគេហទំព័រនេះសម្រាប់បច្ចុប្បន្នភាព ឬការផ្លាស់ប្តូរណាមួយ ។ យើងនឹងជូនដំណឹងអ្នកពីការកែសម្រួលកំណែថ្មីៗនៃគោលការណ៍សិទ្ធិឯកជន ដែលអាចមានឥទ្ធិពលដល់របៀបដែលយើងប្រើ ឬបង្ហាញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ឬព័ត៌មានអ្នកផ្សេងទៀតដែលអ្នកផ្តល់ឲ្យយើង ។

## សំណួរ និងយោបល់

យើងស្វាគមន៍ចំពោះសំណួររបស់អ្នក មតិ និងការព្រួយបារម្ភអំពីសិទ្ធិឯកជន ។
ផ្នែកទំនាក់ទំនងអតិថិជនរបស់ Starbucks អាចទាក់ទងតាមទូរស័ព្ទ ០២៣ ៩៨៦ ៥៩១ ឬតាមរយៈសំបុត្រប្រៃសណីយ៍ខាងក្រោម៖

Cambodia Coffee Concepts (Cambodia) Limited
អគារ Morgan Tower លេខ 388 សាលទី7-11 ជាន់ទី12 ផ្លូវសុភមង្គល ភូមិ 14
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
មជ្ឈមណ្ឌលសេវាកម្មអតិថិជនរបស់កម្មវិធី Starbucks Rewards™ ០២៣ ៩៨៦ ៥៩១